# វប្បធម៌សន្តិភាពតាមរយៈប្រព័ន្ធគំនិតខ្មែរ



ដោយបណ្ឌិត **ណុន សុខា**
ប្រធានផ្នែកអក្សរសាស្ត្រនិងអក្សរសិល្ប៍
វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា

## មូលន័យសង្ខេប

ការរស់នៅរបស់ជនជាតិខ្មែរតែងមានទម្លាប់ផ្សារភ្ជាប់ជីវភាពរបស់ខ្លួនទៅនឹងធម្មជាតិដែលមាននៅជុំវិញខ្លួនរបស់គេ។ គំនិតខ្មែរដែលបានភ្ជាប់ជីវភាពរបស់ខ្លួនទៅនឹងបាតុភូតនេះ គឺក្នុងន័យស្វែងរកភាពស្ងប់ស្ងាត់ខាងផ្លូវចិត្ត ដែលយើងអាចនិយាយបានថា ទង្វើនេះជាប្រព័ន្ធគំនិតមួយកើតចេញពីការយល់ឃើញរបស់ដូនតាយើងអំពីជីវិតនិងធម្មជាតិ ជីវិតនិងការងារប្រចាំថ្ងៃរបស់ខ្លួន។ ប្រព័ន្ធគំនិតនេះកើតមានដំណាលមនុស្សខ្មែរដែរ តែដំបូងឡើយវាមានលក្ខណៈជាសញ្ញាណនៃភាពអរូបី ការជឿលើវិញ្ញាណ ព្រលឹង ឥទ្ធិពលកម្លាំងក្រៅខ្លួននៃធម្មជាតិតែប៉ុណ្ណោះ។ ជាបន្តបន្ទាប់ ប្រព័ន្ធគំនិតខ្មែរដើមនេះក៏ត្រូវបានប្រតិបត្តិព្រមគ្នាជាមួយនឹងទស្សនៈនៃលទ្ធិសាសនាព្រាហ្មណ៍និងសាសនាព្រះពុទ្ធថែមទៀតផង។ ទោះជាយ៉ាងនេះក៏ដោយ វាក៏នៅតែរក្សាខ្លឹមសារជាប្រព័ន្ធគំនិតជាតិជាក់លាក់និងស្ថិតជាប់ក្នុងអារម្មណ៍ប្រជាជនជានិច្ច។ ប្រព័ន្ធគំនិតខ្មែរបានស្តែងតាមរយៈការប្រតិបត្តិផ្សេងៗរបស់ប្រជាជនក្នុងសង្គមជាក់ស្តែង ដូចជា តាមរយៈរូបបដិមា សិល្បៈ រឿងព្រេង ក៏ដូចជាកិច្ចការគ្រប់គ្រងសង្គមនិងនយោបាយផងដែរ។ ជាទូទៅតាមរយៈរឿងព្រេង សិល្បៈ ក៏ដូចជាកិច្ចការសង្គម ត្រូវបានអ្នកសិក្សាស្វែងយល់អំពីអត្ថន័យជាមូលដ្ឋាននិងទាញយកគតិបណ្ឌិតសម្រាប់ទុកជាមេរៀនអប់រំតរៀងមក។

ការលើកយកប្រធានបទ ***វប្បធម៌សន្តិភាពតាមរយៈប្រព័ន្ធគំនិតខ្មែរ*** មកសិក្សា គឺដើម្បីឆ្លុះបញ្ចាំងឱ្យឃើញពីស្មារតីសន្តិភាពរបស់ខ្មែរតាំងពីបុរាណកាលក៏ដូចបច្ចុប្បន្នផងដែរ។ សិក្សារបស់យើងនេះគឺរំលេចតាមរយៈខ្លឹមសារបដិមានៃជំនឿសាសនា ស្ថាបត្យកម្ម ចម្លាក់ សិល្បៈរបាំមួយចំនួន រួមទាំងសិល្បៈក្នុងការធ្វើនយោបាយខ្លះៗផងដែរ។

តាមរយៈប្រព័ន្ធគំនិតនេះ យើងអាចនិយាយបានថា ប្រជាជនខ្មែរពិតមានគំនិតសន្តិភាពនិយមច្រើនជាងគំនិតហិង្សា ហើយ គំនិតសន្តិភាពនេះបានក្លាយជាគោលការណ៍មួយក្នុងការប្រតិបត្តិផ្សេងៗក្នុងសង្គមជាតិតាំងពីយូរលង់ណាស់មកហើយ។ វប្បធម៌សន្តិភាពជាការចាំបាច់បំផុតក្នុងសង្គមជាតិនីមួយៗ ប៉ុន្តែការធ្វើឱ្យមានសន្តិភាពឡើងបាន គឺត្រូវផ្តើមចេញពីភាពស្ងប់ជាចម្បងរបស់បុគ្គលម្នាក់ៗក្នុងការឈានទៅរកសន្តិភាពពិភពលោកផងដែរ។

ដូចនេះ បើមានសន្តិភាព ហើយខ្វះការរក្សាសន្តិភាពក៏ជាបញ្ហាមួយមិនគ្រប់គ្រាន់ដែរ។ ពាក្យថាសន្តិភាពមិនមែនមានន័យត្រឹមតែអវត្តមានសង្គ្រាមនោះទេ។ សន្តិភាពសំដៅដល់ការរស់នៅដែលមានភាពស្ងប់ផ្លូវចិត្ត គ្មានការគំរាមកំហែង គ្មានការភ័យខ្លាចក្នុងការគិត ការបញ្ចេញមតិ ការជួបជុំ ដែលធ្វើឱ្យបុគ្គលម្នាក់ៗមានសេរីភាពនិងជឿជាក់ទុកចិត្តបាន ទើបហៅសន្តិភាពពិតប្រាកដ។

## សេចក្តីផ្តើម

ជនជាតិខ្មែរ ជាជាតិសាសន៍មួយមានវ័យចំណាស់នៅលើទឹកដីរបស់ខ្លួនក៏ដូចជានៅក្នុងតំបន់ឧបទ្វីបឥណ្ឌូចិននេះផងដែរ ព្រមទាំងមានប្រវត្តិសាស្ត្រ អរិយធម៌ច្បាស់ថែមទៀតផង។ តាមការសិក្សារបស់បុរាណវិទូ ប្រវត្តិវិទូបានបង្ហាញឱ្យឃើញថា អរិយធម៌របស់ជនជាតិខ្មែរមានការវិវឌ្ឍជានិច្ចនៅលើទឹកដីឧបទ្វីបឥណ្ឌូចិន ពិសេសនៅលើទឹកដីខ្មែរបច្ចុប្បន្ននេះតាំងពីគ្រាដំបូងនៃការកកើតទឹកដីរហូតមកដល់សព្វថ្ងៃនេះ។ ការកកើតអរិយធម៌នេះ ជាសញ្ញាណមួយបង្ហាញច្បាស់ថា ខ្មែរគឺជាជាតិសាសន៍មានលក្ខណៈពិសេសរបស់ខ្លួននិង ខុសពីជាតិសាសន៍ដទៃទៀត។

*តើលក្ខណៈពិសេសរបស់ខ្លួននេះស្ថិតនៅលើអ្វីដែរ?*

តាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្ន ការរស់នៅរបស់ជនជាតិខ្មែរតែងតែផ្សារភ្ជាប់ជីវភាពរបស់ខ្លួនទៅនឹងធម្មជាតិផ្សេងៗដែលកើតមាននៅជុំវិញនិងក្នុងសង្គមរបស់គេ។ កត្តានេះជាហេតុធ្វើឱ្យខ្មែរមានប្រព័ន្ធគំនិតមួយភ្ជាប់ទៅនឹងរឿងអច្ឆរិយៈផ្សេងៗ កើតបានជាជំនឿដើម្បីរកភាពស្ងប់ស្ងាត់ខាងផ្លូវចិត្ត ក៏ដូចជាការរកសេចក្តីសុខសង្គម។ ពិសេសជាងនេះទៅទៀត រាល់គំនិតនៃជំនឿដែលផ្សារភ្ជាប់នឹងបាតុភូតផ្សេងៗនោះ យើងអាចនិយាយបានថា វាជាប្រព័ន្ធគំនិតខ្មែរមួយដែលកើតចេញពីការយល់ឃើញរបស់ខ្មែរអំពីជីវិតនឹងធម្មជាតិ ជីវិតនឹងការងារប្រចាំថ្ងៃរបស់ខ្លួន ដែលតំណាងឱ្យទស្សនវិជ្ជាខ្មែរក្នុងការអប់រំមនុស្សឱ្យចេះរកភាពសុខដុមក្នុងសង្គមថែមទៀតផង។

ដូច្នេះ ការលើកយកប្រធានបទ ***វប្បធម៌សន្តិភាពតាមរយៈប្រព័ន្ធគំនិតខ្មែរ*** មកសិក្សានេះ ក្នុងន័យស្វែងយល់ថា តើតាមរយៈប្រព័ន្ធគំនិតខ្មែរដែលស្តែងតាមរយៈសិល្បៈក៏ដូចជាគំនិតនយោបាយជាដើម បានបង្កប់នូវខ្លឹមសារនៃវប្បធម៌សន្តិភាពយ៉ាងណាខ្លះ?

## ១- ទស្សនៈខ្លះៗនៃវប្បធម៌សន្តិភាពនិងប្រព័ន្ធគំនិតខ្មែរ

### ១.១- និយមន័យនៃវប្បធម៌សន្តិភាព

ពាក្យថា ***វប្បធម៌សន្តិភាព*** យើងតែងតែបានឮជារឿយៗ សម្រាប់សង្គមខ្មែរក៏ដូចជាសង្គមនៃជាតិសាសន៍ដទៃដែរ។ វប្បធម៌សន្តិភាពត្រូវបានគេចាត់ទុកថាមានសារៈសំខាន់បំផុតក្នុងការអភិវឌ្ឍសង្គមជាតិ។ ជារឿយៗ ក្រសួងដែលពាក់ព័ន្ធក៏ដូចជាក្រសួងអប់រំជាតិតែងបានបង្កើតបរិយាកាសពិភាក្សាឬធ្វើសន្និសីទកម្រិតថ្នាក់ជាតិ អន្តរជាតិ ដើម្បីលើកកម្ពស់ការយល់ដឹង ពង្រឹងវប្បធម៌សន្តិភាពដល់យុវជនមហាជនថែមទៀតផង។

តើពាក្យ ***វប្បធម៌សន្តិភាព*** នេះមានន័យយ៉ាងណា? ហើយអត្ថន័យនេះវាស្តែងឡើងតាមរយៈអារម្មណ៍របស់ប្រជាជនខ្មែរយ៉ាងណាដែរ?

ពាក្យ **វប្បធម៌សន្តិភាព < វប្បធម៌ + សន្តិភាព**

- **វប្បធម៌** មានន័យថា ការផ្សាំបណ្ដុះចំណេះវិជ្ជានិងប្រាជ្ញាស្មារតីឱ្យបានលូតលាស់ចម្រើនដោយវិទ្យាសាស្ត្រឬដោយសិល្បៈផ្សេងៗជាដើម[១]។

- **សន្តិភាព** មានន័យថា ភាពឬដំណើរស្ងប់, សាន្តត្រាណ, រាបទាប; ដំណើរសះជានឹងគ្នា[២]។

ដូចនេះ យើងអាចកំណត់ន័យរួមនៃពាក្យទាំងពីរនេះថា *ការផ្សាំបណ្ដុះនូវចំណេះដឹង ប្រាជ្ញាស្មារតីឱ្យកើតឡើងនិងលូតលាស់ទៅដោយភាពស្ងប់ ដំណើរសាន្តត្រាណ ឬ ដំណើរមិនមានទំនាស់នឹងគ្នា ដំណើរសះជានឹងគ្នា។*

- តាមឯកសារ បេតិកភណ្ឌពិភពលោកក្នុងដៃយុវជន ស្គាល់ ស្រឡាញ់ និង ធ្វើសកម្មភាព, នៅក្នុងអត្ថបទ: ‹ ***បេតិកភណ្ឌពិភពលោកនិងវប្បធម៌សន្តិភាព*** › ផ្សាយដោយអង្គការយូណេស្កូ ឆ្នាំ១៩៩៩ ទំព័រទី២ បានកំណត់ថា***សន្តិភាព*** គឺជា៖
  - (a) ស្ថានភាពជាតិនីមួយៗ-រដ្ឋនីមួយៗដែលគ្មានសង្គ្រាម។
    (b) សន្ធិសញ្ញារវាងអ្នកកំពុងប្រយុទ្ធគ្នាដែលធ្វើការបញ្ចប់សភាពសង្គ្រាម។
  - ទំនាក់ទំនងស្ងប់ស្ងៀមរវាងពលរដ្ឋ អវត្តមាននៃវិបត្តិនិងនៃអំពើហិង្សា។
  - រដ្ឋ លក្ខណៈរបស់តំបន់មួយ ឱកាសមួយ ដែលគ្មានការរំជើបរំជួល ភាពអូអរ។

- **សន្តិភាព** មានន័យថា សេចក្ដីសុខត្រជាក់ត្រជុំឱ្យមានជីវិតរស់នៅដោយប្រពៃ[៣]។

ឯពាក្យ **ប្រព័ន្ធគំនិត** < **ប្រព័ន្ធ + គំនិត**

- **ប្រព័ន្ធ** មានន័យថា សំណុំនៃអន្តរកម្មឬសមាសភាពដែលអាស្រ័យគ្នាទៅវិញទៅមកក្នុងការបង្កើតសំណុំមួយ[៤]។

- **គំនិត** មានន័យថា ការគិត យោបល់[៥]។

ដូចនេះ យើងអាចកំណត់ន័យរបស់ពាក្យទាំងពីរនេះថាជា *សំណុំនៃអន្តរកម្មឬសមាសភាពដែលកើតចេញពីការគិតដោយមានការអាស្រ័យគ្នាទៅវិញទៅមកក្នុងការបង្កើតបានជាអ្វីមួយឬជានិមិត្តរូបអ្វីមួយ ដែលមានអត្ថន័យច្បាស់លាស់*។

កាលណាយើងគិតពីប្រព័ន្ធគំនិតខ្មែរ យើងតែងគិតដល់ផ្នែកជំនឿរបស់ខ្មែរដែលបានផ្សារភ្ជាប់ទៅនឹងបាតុភូតផ្សេងៗ ដែលប្រជាជនខ្មែរបានជួបប្រទះក្នុងជីវភាពរបស់គាត់តាំងពីសម័យបុព្វកាលមក។ ការភ្ជាប់ជំនឿរបស់ខ្លួនទៅនឹងបាតុភូតផ្សេងៗទាំងនោះមានដូចជា ទន្លេ ទីទួល ភ្នំ សត្វ អារក្ស អ្នកតា ជាដើម រហូតមកដល់បច្ចុប្បន្ន បញ្ហាទាំងនេះបានក្លាយទៅជាព្រលឹងនៃវប្បធម៌ជាតិថែមទៀតផង។

## ១.២- សញ្ញាណទូទៅនៃប្រព័ន្ធគំនិតខ្មែរ

---

[១] ជួន ណាត : ***វចនានុក្រមភាសាខ្មែរ*** ភ្នំពេញ, ការផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពគ្រាទី៥ឆ្នាំ១៩៦៧ ទំព័រទី១១៦២។

[២] -ដ- ទំព័រទី១២៥៩។

[៣] សូមមើល ប៉ាង ខាត់ : ***ស្រីហិតោបទេស ភាគទី៤*** ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៩៤ ទំព័រខ-គ។

[៤] សុខ ប៊ុនធឿន : ***ប្រព័ន្ធច្បាប់ខ្មែរ*** ភ្នំពេញ, ឆ្នាំ២០១៤ ទំព័រទី១៥។

[៥] ជួន ណាត : ***វចនានុក្រមភាសាខ្មែរ*** ដ.ឯ.ម. ទំព័រទី១៤៦។

តាមរយៈការសិក្សារបស់ប្រវត្តិវិទូ បានបញ្ជាក់ថាជនជាតិខ្មែរ ជាជាតិសាសន៍មួយមានប្រវត្តិរបស់ខ្លួនពិតប្រាកដ រស់នៅដោយឆ្លងកាត់សម័យបុរេប្រវត្តិសាស្ត្រ សម័យប្រវត្តិសាស្ត្រដ៏យូរលង់មកហើយ។ ក្នុងដំណើរជីវិតដ៏យូរអង្វែងបែបនេះ គេក៏សង្កេតឃើញថា ជនជាតិដ៏ចំណាស់មួយនេះមានប្រពៃណី ទំនៀមទម្លាប់ ទស្សនវិជ្ជារបស់ខ្លួនយ៉ាងពិតប្រាកដនិងច្បាស់លាស់មុននឹងមានទំនាក់ទំនងជាមួយបរទេសទៅទៀត។ ប៉ុន្តែក្រោយពេលខ្មែរមានទំនាក់ទំនងជាមួយឥណ្ឌា ចិន ជាដើម ប្រពៃណី ទំនៀមទម្លាប់ ទស្សនវិជ្ជាដើមរបស់ខ្លួនមួយចំនួន ក៏ត្រូវបានសំយោគចូលជាមួយនឹងវប្បធម៌ថ្មីដែលមានលក្ខណៈស្របនឹងចិត្តគំនិតរបស់ខ្មែរនិងបម្រើឱ្យខ្មែរបន្ថែមលើអ្វីដែលខ្លួនធ្លាប់មានផងដែរ។

ប្រពៃណី ទំនៀមទម្លាប់ ទស្សនវិជ្ជារបស់ខ្មែរសុទ្ធតែបានបង្កប់នូវផ្នត់គំនិតរបស់ខ្មែរយ៉ាងច្បាស់លាស់ ដែលយើងអាចសិក្សាពីខ្លឹមសារនៃប្រព័ន្ធគំនិតនោះបាន។ ជាក់ស្តែងនៅតាមទីកន្លែងដែលប្រជាជនរស់នៅសុទ្ធតែមានឈ្មោះហៅដើម្បីសម្គាល់ទីតាំង ទៅតាមអ្វីដែលពួកគាត់អាចធ្វើទៅបានរហូតដល់ឈ្មោះទីស្ថានដ៏ច្រើនបំផុតនៃប្រទេសកម្ពុជាត្រូវបានបុព្វបុរសយើងប្រឌិតជារឿងព្រេងទុកសម្រាប់ឱ្យកូនចៅជំនាន់ក្រោយងាយចងចាំថែមទៀតផង។ ក្រៅពីនេះ ដូនតាយើងបានបង្កើតនូវជំនឿនិងសិល្បៈផ្សេងៗ ដូចជា អបិយជំនឿ ជំនឿសាសនា របាំ ចម្លាក់ ចម្រៀង ជាដើម។

តើការបង្កើតឱ្យមានអបិយជំនឿ របាំ ចម្លាក់ ... ទាំងនោះបានផ្ទុកនូវប្រព័ន្ធគំនិតខ្មែរយ៉ាងណាខ្លះ?

ខ្មែរជាជាតិសាសន៍ចំណាស់មួយនៅលើទឹកដីរបស់ខ្លួនដែលបានបង្កើតវប្បធម៌របស់ខ្លួនដោយផ្ទាល់។ គេចេះបង្កើតជារឿងព្រេងដើម្បីបង្ហាញពីកំណើតទឹកដី ជនជាតិ ក៏ដូចជាការគ្រប់គ្រងប្រទេសរបស់ខ្លួនផងដែរ ជាក់ស្តែងរឿងព្រះថោងនាងនាគដែលមានខ្លឹមសារទាក់ទងនឹងប្រវត្តិសាស្ត្រ ប្រពៃណីដើមរបស់ជាតិពិតៗ។ យើងដឹងហើយថា នៅដើមសតវត្សរ៍មួយភាគធំនៃជនជាតិនេះបានទទួលអរិយធម៌ពីប្រទេសឥណ្ឌា ជាហេតុញ៉ាំងឱ្យជនជាតិនេះផ្លាស់ប្តូរខ្លះៗនូវទម្រង់វប្បធម៌ នយោបាយ សេដ្ឋកិច្ចរបស់ខ្លួន ហើយ បន្តិចម្តងៗក៏ញ៉ាំងកុលសម្ព័ន្ធនានាឱ្យរលាយចូលគ្នាជាដុំមួយនិងក្លាយទៅជាប្រទេស[៦]។

ការរស់នៅរបស់ប្រជាជនខ្មែរនៅសម័យដើមពិតជាមានជីវភាពលំបាកដោយសារឥទ្ធិពលនៃធម្មជាតិ ដូចជា ទឹកជំនន់ ផ្គររន្ទះ សត្វសាហាវផ្សេងៗ ជាដើម។ ការរស់នៅក្នុងជីវភាពប្រឈមនឹងការលំបាកគ្រប់បែបយ៉ាងនេះ ជាហេតុនាំឱ្យគេត្រូវតែរកបង្អែកខាងស្មារតី ដែលគេជឿថាវាអាចជួយគេបាន។

មុនការហូរចូលនៃសាសនាព្រាហ្មណ៍និងសាសនាព្រះពុទ្ធ ខ្មែរយើងមានជំនឿដើមគឺ តូតឹម[៧]។

តូតឹម សំដៅទៅដល់ការយក វត្ថុ សត្វ រុក្ខជាតិ ឬ បាតុភូតធម្មជាតិ ដែលគេគោរពថាជាសញ្ញារបស់មនុស្ស ក្រុមមនុស្សឬសង្គមណាមួយ ហើយ ជាញឹកញាប់ត្រូវបានគេប្រើក្នុងពិធីជំនឿ ពិធីសាសនារបស់ពួកគេ។ តូតឹមមានតួនាទីសំខាន់ណាស់ក្នុងជំនឿខ្មែរសម័យបុរាណ វាជានិមិត្តរូបឬជាវត្ថុបំណាងមនុស្សក្នុងសង្គមដែលរស់នៅបែបស្វ័យភាព។ រួមមកតូតឹម ជាអ្នកបម្រើបីបាច់ថែរក្សាបុគ្គលណាមួយ ក្រុមមនុស្សណាមួយ ដោយករណីនេះ យើងអាចប្រៀបតូតឹមទៅនឹងព្រលឹង កម្លាំងធម្មជាតិ វិញ្ញាណរបស់បុព្វបុរសឬទេវតា ក្នុងន័យវត្ថុស័ក្តិសិទ្ធិសម្រាប់ថែរក្សាគាំពារលោកឬសង្គមមនុស្ស។ តូតឹមជាគោលពិធីដែលជំនឿតម្រូវដោយមានភ្ជាប់នូវការបូជាចំពោះបុព្វបុរស ដែលទម្លាប់យកព្រលឹងរបស់បុព្វបុរស

---

[៦] មីសែល ត្រាណេ : *ប្រព័ន្ធគំនិតខ្មែរភាគ១* ភ្នំពេញ, រោងពុម្ព [?], ឆ្នាំ១៩៩៨ ទំព័រទី២៦។

[៧] សូមមើល មីសែល ត្រាណេ : *ប្រព័ន្ធគំនិតខ្មែរភាគ១* ដ.ឯ.ម. ទំព័រទី២៦-៣១។

ទាំងនោះនៅតាមថែរក្សានោះឯង។ រហូតមកដល់បច្ចុប្បន្ននេះប្រជាជនខ្មែរមិនថាពេលមានភ័យអាសន្ន ឬពេលមានកិច្ចការអ្វីមួយតែងតែនិយមយកចិត្តទុកដាក់បន់ស្រន់អារក្ស អ្នកតា ដែលមានបំណែកថ្មឬគល់ឈើជាតំណាង នៅកណ្តាលវាលឬក្នុងខ្ទម កាយវិការនេះមិនមានន័យថាគេធ្វើខុសនោះទេ។ គេមិនគោរពបូជាបំណែកថ្មឬគល់ឈើទេ តែគេគោរពបូជាវិញ្ញាណឬព្រលឹងរបស់អ្នកតាដែលគេយល់ថាកំពុងប្រថាប់ក្នុងថ្មឬគល់ឈើនោះទៅវិញ។

សកម្មភាពផ្នែកសតិអារម្មណ៍ទាំងនេះបង្ហាញអំពីប្រព័ន្ធគំនិតជាទស្សនៈរបស់ខ្មែរដែលឱ្យតម្លៃទៅលើកម្លាំងក្រៅខ្លួន ទោះជាធម្មជាតិ ព្រលឹង វិញ្ញាណដូនតា ដែលគេគិតថា វាមានឥទ្ធិពលធ្វើឱ្យគេរស់នៅមានសុភមង្គលឬអពមង្គលទៅបាន។

ដោយសារមានការវិវត្តរីកចម្រើនខាងផ្នែកជីវភាពរស់នៅនៃសង្គមមនុស្សតាមរយៈស្មារតីនេះ សង្គមខ្មែរបុរាណក៏មានការប្រែប្រួលផ្លាស់ប្តូរដែរ។ ទោះបីខ្មែរមានជំនឿរបស់ខ្លួនទៅហើយក្តី ក្រោយពីវប្បធម៌ឥណ្ឌាផ្នែកសាសនាព្រាហ្មណ៍និងសាសនាព្រះពុទ្ធបានចូលមកក្នុងប្រទេសមក ជំនឿទាំងនេះក៏ត្រូវបានខ្មែរទទួលយកមកបន្ថែមទៅលើជំនឿដែលខ្លួនថែមទៀត។ក្នុងរបត់ថ្មីផ្នែកជំនឿនេះខ្មែរក្នុងនាមជាជនជាតិមានប្រព័ន្ធគំនិតច្បាស់លាស់ទៅហើយនោះក៏បានបង្កើតនូវគោលជំនឿមួយដែលមានលក្ខណៈសមស្របនឹងស្មារតី ចិត្តសាស្ត្រ របៀបរបបរស់នៅ ទស្សនវិជ្ជារបស់ខ្លួន ឱ្យចេញជារូបរាងពិតប្រាកដឡើងទ្រទ្រង់នូវប្រព័ន្ធគំនិតខ្មែរដដែល។ គោលជំនឿនោះគឺ ការសំយោគរវាងជំនឿខ្មែរដើមជាមួយនឹងជំនឿសាសនាព្រាហ្មណ៍និងសាសនាព្រះពុទ្ធនេះឯង។ ខ្មែរបានរៀនសូត្រ ក្រេបជញ្ជក់ចំណេះវិជ្ជាពីគម្ពីរនៃសាសនាព្រាហ្មណ៍ក៏ដូចសាសនាព្រះពុទ្ធ ជាក់ស្តែងមានចំណេះដឹងផ្នែកគ្រប់គ្រងប្រទេស ផ្នែកសង្គមកិច្ច ផ្នែកស្ថាបត្យកម្ម ផ្នែកសិល្បៈ អក្សរសាស្ត្រ អក្សរសិល្ប៍ ជាដើម។

ការទទួលនូវពុទ្ធិថ្មីៗបន្ថែមលើប្រព័ន្ធគំនិតដើមរបស់ខ្លួននេះហើយ ដែលធ្វើឱ្យខ្មែរចេះអភិវឌ្ឍជាតិរបស់ឱ្យមានភាពខ្លាំងពូកែខាងវិស័យវប្បធម៌ក៏ដូចជាវិស័យផ្សេងៗទៀត។ យើងអាចនិយាយបានថា នៅក្នុងសម័យដ៏រុងរឿងរបស់ខ្មែរនេះគឺពិតជាកើតឡើងដោយការពិចារណារបស់បុព្វបុរសយើង ស្របតាមបទពិសោធន៍ បច្ចេកទេស មនោគមវិជ្ជាសង្គម លោកទស្សនៈសាសនាមនុស្សនិយម និង សីលធម៌សង្គមនេះឯង។ ពុទ្ធិខាងស្ថាបត្យកម្ម ចម្លាក់ត្រូវបានបុព្វបុរសយើងកសាងឡើងដោយឈរលើទស្សនៈសាសនាផងនិងនិមិត្តរូបផង។ សិល្បៈខ្មែរទាំងស្ថាបត្យកម្ម ទាំងចម្លាក់ សុទ្ធតែមានដំណើរវិវត្តប្រែប្រួលទៅតាមនិន្នាការសាសនានិងជីវភាពសង្គម។ ប្រព័ន្ធគំនិតខ្មែរថ្មីដែលជាបណ្តុំគំនិតរវាងទស្សនៈខ្មែរដើមនិងទស្សនៈនៃសាសនាធំៗទាំងពីរនោះ ក៏ត្រូវបានបុព្វបុរសខ្មែរ សិល្បករខ្មែរបញ្ចូលទៅក្នុងសិល្បៈស្ថាបត្យកម្មនិងចម្លាក់បែបសាសនាទាំងនោះទុកជាទីសក្ការៈ ក្នុងន័យបង្ហាញជានិមិត្តរូបផ្សេងៗផងនិងជាការអប់រំផង។

តាមការសិក្សា យើងឃើញថា វិស័យបដិមាសិល្បៈខ្មែរមានការវិវត្តប្រែប្រួលទៅតាមសម័យកាលប្រវត្តិសាស្ត្រខ្មែរផងដែរ។ នៅចុងសម័យនគរភ្នំបដិមាសិល្បៈធ្វើអំពីថ្មក៏ចាប់ផ្តើមលេចរូបរាងឡើង ហើយមានខ្លឹមសារបម្រើសាសនាធំៗទាំងពីរ ដូចជា បដិមាហរិហរៈ ជាដើម។ នៅសម័យចេនឡា ចុងសតវត្សរ៍ទី៧ អាណាចក្រខ្មែរស្ថិតក្នុងស្ថានភាពពាក់កណ្តាលអនាធិបតេយ្យ ស្នាដៃសិល្បៈស្ថិតលើការចម្លងតាមគំរូចាស់ៗ ដោយរក្សាទុកព្រលឹងសិល្បៈនៃភាពរស់រវើកក្នុងការច្នៃប្រឌិតនិងបានផលិតស្នាដៃ

ពិតប្រកបដោយតម្លៃរស់រវើករបស់ខ្លួន[៨]។ មកដល់សតវត្សរ៍ទី៩ យើងឃើញថា សិល្បករខ្មែរបានប្រើប្រាស់វប្បធម៌ក្រៅប្រទេសគួបផ្សំជាមួយទុនសិល្បៈជាតិ ដើម្បីបង្កើតទម្រង់សិល្បៈជាតិមួយ នេះជាការច្នៃប្រឌិតថ្មីបានផុសឡើងនៅចុងសម័យនោះ។ សម័យកកើតទីក្រុងអង្គរ សិល្បករចូលចិត្តឆ្លាក់រូបធំៗមានទម្រង់ជាជីវិតធម្មតា បម្រើប្រយោជន៍មនុស្សជាក់ស្តែង[៩]។ មកដល់សតវត្សរ៍ទី១២ សិល្បករបានកសាងបដិមាសិល្បៈដោយឱ្យតម្លៃទៅលើការតុបតែងលម្អដោយអលង្ការច្រើនជាងធម្មជាតិនិយម។ មកដល់សតវត្សរ៍ទី១៣ បដិមាសិល្បៈស្ថិតក្នុងទស្សនៈសាសនាព្រះពុទ្ធ សិល្បករកសាងបដិមាដោយយកចិត្តទុកដាក់លើសម្ផស្សមុខ ភ្នែកបិទពាក់កណ្តាល បបូរមាត់ញញឹម ក្នុងន័យសមាធិឬមនោសញ្ចេតនាផ្សេងៗ។

សរុបមក យើងឃើញថា ប្រព័ន្ធគំនិតខ្មែរបានកើតមានតាំងពីដំណាលមនុស្សខ្មែរមកម្ល៉េះ ដែលប្រព័ន្ធគំនិតនេះដំបូងឡើយវាមានលក្ខណៈជាសញ្ញាណនៃភាពអរូបី ជឿលើវិញ្ញាណ ព្រលឹង ឥទ្ធិពលកម្លាំងក្រៅខ្លួនឬធម្មជាតិតែប៉ុណ្ណោះ។ ប៉ុន្តែជាបន្តបន្ទាប់ ប្រព័ន្ធគំនិតខ្មែរដើមនេះក៏ត្រូវបានសំយោគជាមួយនឹងទស្សនៈនៃលទ្ធិសាសនាព្រាហ្មណ៍និងសាសនាព្រះពុទ្ធ ដោយនៅតែរក្សានូវខ្លឹមសារទ្រទ្រង់ប្រព័ន្ធគំនិតជាតិមួយជាគោលជាក់លាក់ ហើយ ក៏កំពុងស្ថិតជាប់ក្នុងអារម្មណ៍ប្រជាជនរហូតដល់សព្វថ្ងៃនេះផងដែរ។ ជារួមយើងអាចនិយាយបានថា ប្រព័ន្ធគំនិតខ្មែរទាំងនេះបានស្តែងតាមរយៈការប្រតិបត្តិផ្សេងៗរបស់ប្រជាជនក្នុងសង្គមជាក់ស្តែងតាមរយៈបដិមាសិល្បៈក៏ដូចជាកិច្ចការគ្រប់គ្រងសង្គមផងដែរ។

## ១.៣- សញ្ញាណទូទៅនៃវប្បធម៌សន្តិភាព

វប្បធម៌សន្តិភាព មានន័យថា *ការផ្សាំបណ្តុះនូវចំណេះដឹង ប្រាជ្ញា ស្មារតីឱ្យកើតឡើងនិងលូតលាស់ទៅដោយភាពស្ងប់ ដំណើរសាន្តត្រាណ ឬ ដំណើរមិនមានទំនាស់នឹងគ្នា ដំណើរសះជានឹងគ្នា។* នៅក្នុងបុព្វបទនៃរដ្ឋធម្មនុញ្ញរបស់អង្គការយូណេស្កូបានសរសេរថា *ដោយសង្គ្រាមចាប់ផ្តើមនៅក្នុងចិត្តរបស់មនុស្ស គឺនៅក្នុងចិត្តរបស់មនុស្សនេះហើយដែលការពារសន្តិភាពត្រូវតែកសាងឡើង។*

តើសន្តិភាពជាអ្វី? សន្តិភាពទាមទារការរក្សានូវទំនាក់ទំនងអហិង្សា មិនត្រឹមតែរវាងប្រទេសទេ តែរវាងបុគ្គល រវាងក្រុមសង្គម រវាងប្រទេសនិងពលរដ្ឋរបស់គេ និង រវាងមនុស្សនិងបរិស្ថានរបស់គេផងដែរ។ ចំណេះដឹងខាងផ្នែកវប្បធម៌សង្គមក៏បានជួយយើងឱ្យយល់នូវខ្លឹមសារសន្តិភាព និង មនុស្សដ៏មហាអស្ចារ្យ ដែលភាគច្រើនឆ្លុះបញ្ចាំងនូវសេចក្តីប្រាថ្នាជាអមតៈចំពោះសិទ្ធិសេរីភាព យុត្តិធម៌ ការយល់ដឹង និង ការគោរពគ្នាទៅវិញទៅមក សេចក្តីស្នេហានិងមិត្តភាព ជាដើម។ តម្លៃទាំងនេះបង្ហាញនូវច្បាប់សំខាន់ៗនិងគ្រឿងផ្សំមិនអាចអត់បាននៃសន្តិភាពនិងការអភិវឌ្ឍសម្រាប់បុគ្គលម្នាក់ៗ សង្គមនីមួយៗ និងពិភពលោកទាំងមូលផងដែរ។

ចលនាវប្បធម៌សន្តិភាព ប្រៀបបានដូចជាទន្លេដ៏ធំមួយពោរពេញដោយចរន្តផ្សេងៗ ដូចជា ប្រពៃណី វប្បធម៌ ភាសា សាសនា ទស្សនៈនយោបាយ ជាដើម។ គោលបំណងសំខាន់នៃចលនាវប្បធម៌សន្តិភាពគឺ ពិភពលោកមួយដែលសម្បូរទៅដោយវប្បធម៌រួមរស់ជាមួយគ្នាក្នុងបរិយាកាសនៃការយល់អន្តរវប្បធម៌ ការអធ្យាស្រ័យ និង សាមគ្គីភាព។

---

[៨] សូមមើល ដុច គឿន : ***មនុស្ស សិល្បៈ ជំនឿ*** ភ្នំពេញ, ការផ្សាយរបស់គណៈកម្មការស្រាវជ្រាវសាកលវិទ្យាល័យវិចិត្រសិល្បៈ, ឆ្នាំ១៩៩៣ ទំព័រទី២៥។

[៩] -ដ- ទំព័រទី២៨។

តើវប្បធម៌សន្តិភាពនេះអាចកើតឡើងយ៉ាងដូចម្តេច?

សន្តិភាពជាដំណើរស្ងប់ទាំងផ្លូវកាយនិងផ្លូវចិត្ត ឬសំដៅដល់ក្តីស្រឡាញ់ ក្តីមេត្តា ការសន្តោសប្រណី ការអធ្យាស្រ័យ និង យុត្តិធម៌។ ក្តីមេត្តា ជាចំណុចផ្តើមនូវសន្តិភាព ព្រោះក្នុងករណីដែលយើងមានការអាណិត ការជួយសង្គ្រោះដល់បុគ្គលណាមួយ គេនឹងទទួលបាននូវសេចក្តីស្រឡាញ់ពីយើង គេនឹងស្រឡាញ់រាប់អានយើងវិញ។ យ៉ាងនេះ ដើម្បីទទួលបាននូវសន្តិភាពពិតប្រាដក ទាមទារឱ្យបុគ្គលគ្រប់រូបចាប់ផ្តើមស្វែងយល់ពីការតាំងចិត្តចំពោះខ្លួនឯងជាមុនសិន ដោយចេះអនុវត្តនូវគោលការណ៍មួយចំនួនដូចជា ៖

- ការធ្វើសមាធិ ការធ្វើសមាធិមិនត្រឹមតែជួយឱ្យយើងមានសុខភាពផ្លូវចិត្ត ផ្លូវកាយប៉ុណ្ណោះទេ តែវាអាចបង្កើឱ្យមានក្តីមេត្តា អាចទប់ស្កាត់នូវកំហឹងក្នុងខ្លួនឬការបង្កើតទម្លាប់ក្នុងការបំបាត់នូវភាពក្រេវក្រោធក្នុងចិត្តបានទៀតផង។

- ការស្វែងយល់អំពីទំនាស់ ការស្វែងយល់ពីឫសគល់នៃបញ្ហាទំនាស់ ស្វែងយល់ពីពហុវប្បធម៌ របៀបរបបរស់នៅផ្សេងៗនៃសង្គមមនុស្សឱ្យបានច្បាស់លាស់។ នៅពេលយើងយល់ពីគេហើយ គេក៏យល់ពីយើងដោយការគោរពនិងឱ្យតម្លៃគ្នាទៅវិញទៅមកដែរ។

- អហិង្សាវិធី ការប្រកាន់នូវអហិង្សាវិធី ជាការមិនតបតកំហឹងទល់នឹងកំហល់ យើងអាចនិយាយបានថា វិធីនេះជាការយកដុំទឹកកកទៅពន្លត់ភ្លើងក្តៅ ដែលជាហេតុធ្វើឱ្យយើងមានគំនិតសុទិដ្ឋនិយម។

- ការមានសីលធម៌ក្នុងខ្លួន គឺសំដៅដល់សីលធម៌ទាំងប្រាំមាន៖ *បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ និង សុរាមេរ័យ។*

ការបង្កើតវប្បធម៌សន្តិភាពនៅក្នុងខ្លួននេះ ត្រូវបានអ្នកប្រាជ្ញល្បីៗ ដូចជា អ្នកចិត្តសាស្ត្រ ទស្សនវិទូ ជាដើម តែងណែនាំមនុស្សឱ្យយល់និងចេះរក្សាសន្តិភាពដោយការរស់នៅជាមួយគ្នាឱ្យចេះយោគយល់គ្នា ណែនាំឱ្យមនុស្សយល់ពីប្រភពនៃការកើតសន្តិភាព ដែលកើតឡើងតាមរយៈផ្លូវកាយ ផ្លូវចិត្ត និង រូបរាងកាយខាងក្រៅរបស់បុគ្គល ជាដើម។

និយាយរួម សន្តិភាពអាចកើតមានឡើតទៅបានគឺពុំមែនគ្រាន់តែប្រទេសគ្មានសង្គ្រាម ការមិនបំពានលើរាងកាយ ការមិនប្រើអំពើហិង្សាដោយកម្លាំងបាយនោះទេ តែសន្តិភាពពិតប្រាកដទាល់តែបុគ្គលទទួលបាននូវសន្តិភាពផ្លូវចិត្ត គ្មានការគំរាមកំហែង គ្មានការភ័យខ្លាច ហើយសេរីភាពនៃការគិត ការបញ្ចេញមតិ ការជួបជុំ ការរស់នៅ ការធ្វើនយោបាយ ជំនឿ ត្រូវបុគ្គលម្នាក់ៗទទួលបានពិតប្រាកដ មានន័យថា*អវត្តមានសង្គ្រាម ពុំមែនមានន័យថា សុទ្ធតែជាសន្តិភាពនោះទេ។*

## ២- អត្ថន័យវប្បធម៌សន្តិភាពតាមរយៈរូបភាពផ្សេងៗនៃប្រព័ន្ធគំនិតខ្មែរ

ប្រព័ន្ធគំនិតខ្មែរត្រូវបានបង្កប់ក្នុងជំនឿ ស្នាដៃសិល្បៈ ស្ថាបត្យកម្ម រឿងព្រេងបុរាណនានា ជាដើម។ យ៉ាងនេះយើងឃើញថា ទោះបីជាប្រាង្គប្រាសាទខ្មែរដែលបានសង់ឡើងតាមសិល្បារម្មណ៍សាស្ត្រនិមិត្តរូបនិយម កាត់ផ្តាច់សិល្បៈអំពីតថភាពក៏ដោយចុះ ក៏យើងនៅតែងមើលឃើញនូវការចាំងត្រឡប់មកវិញនូវផ្ទាំងរូបភាពនៃជីវិតនៅក្នុងនិម្មិតកម្មសិល្បៈនោះជាដរាប។ បុព្វបុរសខ្មែរតែងបញ្ចូលគំនិតមនុស្សនិយមនៅគ្រប់ទម្រង់សិល្បៈ។ តាំងពីបណ្តាសតវត្សរ៍ខាងដើមរហូតមកដល់សតវត្សរ៍ទី១៣ សិល្បៈសំណង់ស្ថាបត្យកម្មខ្មែរត្រូវបានកសាងឡើងដើម្បីបម្រើផលប្រយោជន៍មនុស្សនិងសង្គមមនុស្សតែប៉ុណ្ណោះ។ សិល្បករខ្មែរបានធ្វើឱ្យអ្នកមើលប្រាសាទខ្មែរឃើញថា អ្វីៗជាការកើតឡើងពីពល

កម្មរបស់មនុស្សពិតៗ។ ការជឿលើអាទិទេព ក្នុងគំនិតខ្មែរបានក្លាយមកជាមនុស្ស*អាទិទេពគឺស្តេច។* នាភាគខាងដើមនៃសតវត្សទី៩មក ស្ថាបនិក សិល្បករខ្មែរបានបង្កប់កម្លាំងមនុស្សនិយមពាក់កណ្តាលទៅក្នុងកេតនភណ្ឌជាតិខ្មែររួចស្រេចទៅហើយ[១០]។

ស្នាដៃសិល្បៈទាំងឡាយ ទោះជាបដិមាសិល្បៈ សិល្បៈតុបតែងលម្អ របាំ ស្ថាបត្យកម្ម ជាដើម គ្រប់ទម្រង់សិល្បៈទាំងនោះតែងបញ្ជាក់ប្រាប់អ្នកមើលអំពីខ្លឹមសារពិតរបស់វាតាមរយៈនិមិត្តរូបជានិច្ច។ និមិត្តរូបក្នុងសិល្បៈស្ថាបត្យកម្ម ក៏ដូចជាក្នុងរបាំ និង ក្នុងបដិមាសិល្បៈដែរ តែងមានខ្លឹមសារពីរជានិច្ច ខ្លឹមសារទីមួយគឺការបង្ហាញអំពីជីវិត ជាជីវិតប្រឆាំងនឹងធម្មជាតិ ជីវិតក្នុងធម្មជាតិ និង ខ្លឹមសារមួយទៀតជាការបង្ហាញប្រាប់នូវមនោគមវិជ្ជារួមរបស់ម័យកាល។

ខាងក្រោមនេះ ជាតម្លៃសិល្បៈក្នុងការបម្រើប្រយោជន៍មនុស្សដែលមានខ្លឹមសារដូចតទៅ៖

## **២.១- អត្ថន័យសន្តិភាពតាមរយៈការប្រតិបត្តិជំនឿផ្សេងៗ**

តាមការសិក្សាពីប្រព័ន្ធគំនិតខ្មែរក៏ដូចជាការស្វែងយល់ជាក់ស្តែង យើងអាចនិយាយបានថាប្រជាជនខ្មែរជាជាតិសាសន៍មួយមានគំនិតសន្តិភាពនិយមច្រើនជាងគំនិតហិង្សា។ គំនិតសម្របសម្រួលក៏យើងអាចនិយាយបានថា ជាគោលការណ៍មួយក្នុងការប្រតិបត្តិផ្សេងៗក្នុងសង្គមជាតិផងដែរ។ ជាក់ស្តែង ទោះជាខ្មែរមានប្រព័ន្ធគំនិត មានជំនឿតាំងពីបុរាណរបស់ខ្លួនយ៉ាងណាក៏ដោយ ប៉ុន្តែក្រោយពីខ្មែរបានចាប់យកជំនឿសាសនាធំៗពីរ គឺសាសនាព្រាហ្មណ៍និងសាសនាព្រះពុទ្ធដែលចូលមកពីឥណ្ឌាមកនោះ ក៏ខ្មែរមិនចោលនូវជំនឿដើមរបស់ខ្លួនដែរ។ ករណីដូចជា រហូតមកដល់សព្វថ្ងៃនេះ ការប្រតិ-បត្តិជំនឿខ្មែរដើមនិងជំនឿសាសនា ត្រូវបានខ្មែរប្រតិបត្តិព្រមគ្នា ករណីនេះ ចំពោះអ្នកមិនដឹងច្បាស់អំពីបញ្ហានៃភាពខុសគ្នាក្នុងជំនឿខ្មែរដើមនិងជំនឿសាសនានេះ គេអាចយល់ថាជារឿងតែមួយទៀតផង។ យើងសង្កេតឃើញថា ក្នុងវត្តព្រះពុទ្ធសាសនាសព្វថ្ងៃ ជារូបភាពបង្ហាញថា ជាការគោរពប្រតិបត្តិសាសនាព្រះពុទ្ធទេ ប៉ុន្តែជាក់ស្តែង ការប្រតិបត្តិនេះតើមានអ្វីខ្លះដែលមិនមែនជាធាតុនៃសាសនាព្រះពុទ្ធនោះ។ យើងសង្កេតឃើញថា គ្រប់វត្តព្រះពុទ្ធសាសនា ក្នុងវត្តនីមួយៗមានខ្ទមអ្នកតាដែលជាជំនឿខ្មែរដើមត្រូវបានប្រជាជនគោរពដែរ។ គ្រឿងសក្ការៈបូជាមានបាសី ស្លាធម៌បែបសាសនាព្រាហ្មណ៍ក៏មាន ព្រះសង្ឃដែលបួសតាមសាសនាព្រះពុទ្ធ លោកចេះវិធីក្បួនផ្សេងៗនៃគម្ពីរសាសនាព្រាហ្មណ៍ ដូចជា ព្រះសង្ឃខ្លះចេះមន្តអាគមអូមអាម ស្រោចទឹកលើករាសី រំដោះគ្រោះ ទស្សន៍ទាយតាមបែបសាសនាព្រាហ្មណ៍ជាដើម។

សរុបមក ការប្រតិបត្តិជំនឿសាសនាបែបនេះ បង្ហាញពីភាពសុខដុមមួយដែលប្រជាជនបានប្រកាន់យកតាំងពីយូរយារណាស់មកហើយ។ ស្មារតីនេះក៏ជាប្រព័ន្ធគំនិតសន្តិភាពនិយមមួយរបស់ប្រជាជនខ្មែរតាំងពីបុរាណកាលដែរ។

## **២.២- អត្ថន័យសន្តិភាពតាមរយៈស្នាដៃសិល្បៈ**

### **ក- សិល្បៈចម្លាក់**

**- បដិមា ហរិហរៈ**

បដិមា**ហរិហរៈ** ជាបដិមាមួយត្រូវបានបង្កើតឡើងតាមប្រព័ន្ធគំនិតនៃការបង្រួបបង្រួមដោយយកទេវៈពីររួមបញ្ចូលជាទេវៈតែមួយ។ បដិមានេះត្រូវបានរកឃើញនៅប្រទេសខ្មែរក្នុងអំឡុងសតវត្សរ៍

---

[១០] ជុច ភឿន : ***មនុស្ស សិល្បៈ ជំនឿ*** ដ.ឯ.ម. ទំព័រទី៥៦។

ទី៦។ បដិមា **ហរិហរៈ** មួយចំហៀងខាងស្តាំជាអាទិទេពសិវៈ ឬហៅថា *ហរៈ* និងមួយចំហៀងខាងឆ្វេងជាអាទិទេពវិស្ណុ ឬហៅថា *ហរិ* ដែលអាទិទេពទាំងពីរនេះជាអាទិទេពដ៏សំខាន់ៗក្នុងសាសនាព្រាហ្មណ៍។

យើងអាចយល់បានថា ក្នុងដំណាក់កាលនៃការបង្កើតបដិមា **ហរិហរៈ** នេះប្រាកដជាអ្នកគោរពសាសនាព្រាហ្មណ៍នេះ ស្ថិតក្នុងដំណាក់កាលមួយនៃទំនាស់វិបត្តិសាសនា រវាងអ្នកគោរពសាសនាព្រាហ្មណ៍និកាយវិស្ណុនិងអ្នកគោរពសាសនាព្រាហ្មណ៍និកាយសិវៈ។ អ្នកប្រាជ្ញសាសនាដែលបានបង្កើតរូបបដិមាហរិហរៈនេះឡើង គឺក្នុងគោលបំណងបង្រួបបង្រួមអ្នកកាន់សាសនាព្រាហ្មណ៍និយកាយទាំងពីរនេះកុំឱ្យមានវិបត្តិនឹងគ្នា មានន័យថា អ្នកគោរពសាសនាព្រាហ្មណ៍និកាយវិស្ណុក៏ដូចជានិកាយសិវៈគោរពបដិមាតែមួយ។ ការធ្វើបែបនេះបានធ្វើឱ្យអ្នកគោរពសាសនាព្រាហ្មណ៍និកាយទាំងពីរនេះសុខចិត្តទទួលយកទាំងសងខាង។ នេះជាមធ្យោបាយផ្សះផ្សារបង្រួបបង្រួមជាតិមួយតាមរូបមន្តឯកភាពក្នុងបដិភាព គឺការធ្វើឱ្យបុគ្គលដែលមានវិបត្តិនឹងគ្នាក្នុងការគោរពអាទិទេពទាំងពីរនេះមានភាពសុខសាន្តនឹងគ្នាយ៉ាងពិតប្រាកដ។

- **ស្ថាបត្យកម្មប្រាសាទបាយ័ន**

ក្រោយពីវត្តមាននៃសាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនាមហាយានបានចូលមកដល់ប្រទេសកម្ពុជា សាសនាទាំងពីរនេះបានវិវត្តរីកចម្រើនក្នុងសង្គមខ្មែរជាបន្តបន្ទាប់ ទោះជាប្រជាជនខ្មែរប្រកាន់សាសនាណាមួយខ្លាំងជាងណាមួយក៏ដោយ។ នៅសតវត្សរ៍ទី៨នៃគ្រិស្តសករាជ ប្រទេសកម្ពុជាត្រូវបានបែងចែកទឹកដីជាពីរ គឺចេនឡាដែនទឹកនិងចេនឡាដែនគោក។ ដោយសារប្រទេសមានអស្ថេរភាព ជាហេតុនាំឱ្យនយោបាយ សេដ្ឋកិច្ច និង សង្គមកិច្ចក្នុងសង្គមជាតិរួមទាំងវិស័យសិល្បៈផងក៏ត្រូវចុះដុនដាប អន់ថយបាត់បង់នូវសញ្ញាណច្នៃប្រឌិត។ មនសិការសង្គមផ្នែកជំនឿសាសនាក៏បានចែកចេញជានិកាយ ដែលជាហេតុនាំឱ្យមនុស្សមានការបែងចែកជាក្រុមប្រកាន់និកាយក្នុងជំនឿផ្សេងៗគ្នាដែរ។ ដោយមានការយល់ឃើញនិងជៀសវាងកុំឱ្យមានការបែកបាក់ជាតិ សិល្បករជំនាញបានបង្កើតនូវវិធីបង្រួបបង្រួមនិកាយផ្សេងៗទាំងនោះឱ្យចូលមកក្នុងមនសិការប្រមូលផ្តុំតែមួយវិញ។ ជាក់ស្តែង យើងឃើញមានការបង្កើតបដិមាហរិហរៈ ដើម្បីបង្រួបបង្រួមនិកាយពីរនៃសាសនាព្រាហ្មណ៍ឱ្យមកតែមួយ ធ្វើឱ្យក្រុមនិកាយវិស្ណុក៏អាចគោរពបដិមាហរិហរៈបាន និកាយសិវៈក៏អាចគោរពបាន ក្នុងន័យបញ្ចប់ការបែកបាក់គ្នាក្នុងសាសនាតែមួយ។

ដោយឡែកនៅសតវត្សរ៍ទី១៣ ស្ថាបត្យកម្មប្រាសាទបាយ័នបានឆ្លើយតបទៅនឹងគំនិតបង្រួបបង្រួមជាតិនេះដែរ។ នៅដើមសតវត្សរ៍ទី១០ ព្រះបាទយសោវរ្ម័នដែលជាអ្នកកសាងទីក្រុងអង្គរមុនគេនិងមើលឃើញនូវមេរៀនប្រវត្តិសាស្ត្រអំពីការបែកបាក់ ប្រេះឆារក្នុងសង្គមដោយកត្តាសាសនានិងកត្តាដទៃទៀតនៃរបបនយោបាយនិងសេដ្ឋកិច្ច ព្រះអង្គបានចាប់អារម្មណ៍ យកចិត្តទុកដាក់ជាបឋមក្នុងការគិតគូរដល់មូលដ្ឋានកសិកម្មនិងមូលដ្ឋាននៃជំនឿ។ ព្រះបាទយសោវរ្ម័នបានចាត់ឱ្យគេសាងសង់វត្តអារាមចំនួន៣សម្រាប់បម្រើនិកាយវិស្ណុ និកាយសិវៈ និង និកាយសិវៈនិងពុទ្ធសាសនា[១១]។ ប្រាសាទបាយ័នបានបង្កប់នូវទស្សនៈពីរសំខាន់ គឺទស្សនៈសាសនានិងទស្សនៈនយោបាយ។ ប្រជាជនគ្រប់ស្រទាប់ក្នុងសង្គមអាចទទួលយកបានប្រាសាទនេះជាទីសក្ការៈបូជារបស់ខ្លួនដែរ ទោះបីបុគ្គលណាមួយគោរពជឿ

[១១] ជុច ភឿន : *មនុស្ស សិល្បៈ ជំនឿ* ជ.ឯ.ម. ទំព័រទី៦៣។

លើសាសនាព្រាហ្មណ៍ឬពុទ្ធសាសនាក៏ដោយក៏អាចយកប្រាសាទបាយ័ននេះជាទីគោរពបូជាតាមជំនឿរៀងៗខ្លួន។ ប្រាង្គប្រាសាទមានមុខបួន បានបង្ហាញប្រាប់នូវគំនិតពីរ គឺអ្នកគោរពសាសនាព្រាហ្មណ៍ទទួលស្គាល់ថា ជាមុខព្រហ្ម(អាទិទេពព្រះព្រហ្ម) និង ពួកគោរពពុទ្ធសាសនាទទួលស្គាល់ថា ជាមុខរបស់ពោធិសត្វ លោកេស្វរៈ។

ដូចនេះ តាមរយៈសិល្បៈនៃការកសាងប្រាសាទបាយ័នមានមុខបួននេះ ដោយទម្រង់មុខមានភាពញញឹមរីករាយ បែបលក្ខណៈបរិសុទ្ធ ត្រេកអរ ករុណា បង្ហាញថាបុព្វបុរសយើងមានគំនិតវៃឆ្លាតក្នុងការបង្រួបបង្រួមផ្នែកអារម្មណ៍មនុស្សជាអ្នកជឿលើសាសនាឱ្យមានចិត្តស្ងប់ ទទួលយកដោយក្តីរីករាយនិងសាទរអស់ពីចិត្តតាមរយៈកាយវិការនៃការគោរពបូជានេះឯង។ សិល្បៈស្ថាបត្យកម្មនៃប្រាសាទបាយ័ននេះពិតជាបានបង្ហាញនូវសិល្បារម្មណ៍សាស្ត្រនៃវប្បធម៌សន្តិភាពពិតៗ។

- **ចម្លាក់ទេវតានិងយក្សនៅផ្លូវចេញចូលប្រាសាទបាយ័ន**

នៅមុខខ្លោងទ្វារប្រាសាទបាយ័ន យើងឃើញមានចម្លាក់ថ្មធំៗនៅអមសងខាងផ្លូវចេញចូលប្រាសាទ។ ចម្លាក់នោះគឺជារូបតាងទេវតាម្ខាង និង យក្សម្ខាង ឈរឱបទាញនាគក្បាល៥។

តើចម្លាក់ទាំងនេះជាអ្វី? ហើយជានិមិត្តរូបអ្វីដែរ?

មានអ្នកស្រាវជ្រាវជាច្រើនបានបញ្ចេញទស្សនៈផ្សេងៗគ្នាចំពោះរូបចម្លាក់នេះ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ទស្សនៈទាំងនោះសុទ្ធតែបានបង្ហាញពីលក្ខណៈខ្លាំងរបស់ខ្មែរឬបង្ហាញនូវរូបារម្មណ៍ផ្សេងៗធ្វើឱ្យខ្មែរមានមោទនភាពជាតិជាទីបំផុត។ មតិខ្លះលើកឡើងថា រូបចម្លាក់នេះជានិមិត្តរូបនៃការកូរសមុទ្រទឹកដោះ ដែលមានខ្លឹមសារជានិមិត្តរូបនៃ*និរន្តរភាពឬភាពអមតៈនៃលោកយើងនេះ*។ ក្នុងជំនឿសាសនាព្រាហ្មណ៍ ទេវៈឬទេវតាតំណាងឱ្យសភាវៈល្អ រីឯពួកយក្សតំណាងឱ្យសភាវៈអាក្រក់ អង្គទាំងពីរនេះជាកម្លាំងពីរផ្ទុយគ្នា មិនអាចរស់នៅឬសហការគ្នាបានទេ។ ប៉ុន្តែផ្ទុយទៅវិញ តាមរយៈចម្លាក់នេះ យើងឃើញថា សភាវៈទាំងពីរនេះរួមទាំងសត្វនាគផងបានរួបរួមគ្នាជាកម្លាំងដើម្បីផលប្រយោជន៍ដែលខ្លួនប៉ងប្រាថ្នាទៅវិញ។ សិល្បៈនេះ ទោះបីមានប្រភពតាមជំនឿសាសនាព្រាហ្មណ៍ តែខ្មែរយើងបានពិចារណានិងយកមកតុបតែងក្នុងន័យអប់រំផង គោរពផង និង លម្អផង។ ខ្លឹមសារអប់រំស្ថិតនៅត្រង់ចំណុចសំខាន់ដែលយើងត្រូវពិចារណាលើការរួបរួមនៃអង្គទាំងបីដែលធ្លាប់ជាសភាវៈតំណាងឱ្យភាពមិនចុះសម្រុងនឹងគ្នាតែត្រឡប់មកជាការរួបរួមមួយក្នុងការងារធំទៅវិញ។ នេះបញ្ជាក់ថា តាមរយៈសិល្បៈចម្លាក់ជាចំណុចចាប់ផ្តើមនៃចលនាសន្តិភាពនិយម ការបង្កើតឱ្យមានស្ថិរភាពក្នុងលោកដែលមានលក្ខណៈអមតៈ។

ដូចនេះ យើងអាចនិយាយបានថា ចម្លាក់នេះជាសិល្បៈមានអត្ថន័យសន្តិភាពនិយមមួយក្នុងការអប់រំចិត្តកូនខ្មែរឱ្យយល់បានកាន់តែច្បាស់អំពីសាមគ្គីភាព ការរួបរួម សហការ និង ស្មារតីភាតរភាព។

**ខ- សិល្បៈរបាំ**

របាំស្នែងទន្សោងមានដំណាលថា មានព្រានព្រៃម្នាក់ឈ្មោះពរ ទទួលព្រះរាជបញ្ជាពីព្រះរាជាឱ្យចេញទៅបាញ់ទន្សោង។ ព្រាននោះចេញទៅបាត់យូរណាស់ ទើបត្រឡប់មកចូលគាល់ព្រះរាជាវិញដោយដៃទទេ។ ព្រះរាជាក៏ត្រាស់សួរថា ហេតុអ្វីក៏ពុំបានសត្វទន្សោងមួយសោះដូច្នេះ? ព្រានពរក៏ក្រាបបង្គំទូលថា ខ្លួនបានដើរទៅដល់ព្រៃដែលសម្បូរទៅដោយសត្វទន្សោងនិងម្រឹកដទៃៗ។ ប៉ុន្តែដោយទូលបង្គំរវល់តែមើលទស្សនីយភាពមួយយ៉ាងចម្លែក គឺមានសត្វទន្សោងញីឈ្មោលមួយគូ វាចេះ

រាំយ៉ាងល្អ នាំឱ្យជក់ចិត្តមិនអាចបាញ់វាកើតឡើយ។ ទូលបង្គំផ្គងស្នាលើស្នា លបៗចូលទៅ ប្រុងតែនឹងបាញ់ដែរ តែដោយល្អមើលក្បាច់ចង្វាក់រេរាំរបស់សត្វនេះពេកក៏ខកខាន រកតែដម្លោះព្រួញឱ្យត់ទៅមិនកើត។ មិនតែប៉ុណ្ណោះ មានខ្លាធំមួយដែលលបមកប្រុងនឹងចាប់ទន្សោងដែរនោះ ក៏ចាប់មិនកើត បែរជាជួយគោះជើងជាចង្វាក់ឱ្យទន្សោងរាំទៅវិញ។ ជាមួយនឹងក្បាច់រាំរបស់ទន្សោងនេះ មានកន្លង់មួយហ្វូងហើរស្រែកប្រទក្សិណជុំវិញទន្សោងទាំងពីរ ជួយធ្វើជាសូរសំនៀងពីរោះល្វេងល្វើយ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ក៏ត្រាស់បង្គាប់ឱ្យព្រានពរធ្វើត្រាប់តាមទស្សនីយភាពនោះថ្វាយព្រះអង្គ។ ព្រានពរក៏ខំធ្វើត្រាប់ឱ្យបានកាយវិការនិងសំឡេងសត្វថ្វាយព្រះរាជាទ្រង់ទតនិងទ្រង់ព្រះសណ្ដាប់គ្មានសល់ចន្លោះអ្វី។

ការសម្ដែងកាយវិការរបស់ព្រានពរនេះហើយ ដែលកើតបានទៅជារង់របាំស្នែងទន្សោងនេះឡើង ដោយមានអ្នកពាក់ស្នែងទន្សោងពីរនាក់ជាតំណាងទន្សោងញីឈ្មោល សំឡេងស្គរតំណាងសន្ទឹកខ្លាធំ សំឡេងពួយជាតំណាងសូរសព្ទសត្វកន្លង់។

តាមរឿងនិទានដែលបង្ហាញពីប្រភពនៃរបាំនេះ យើងឃើញមានតួអង្គសំខាន់ៗគឺៈ

- ព្រានពរ ជាអ្នកបរបាញ់សត្វថ្វាយព្រះរាជា,
- ខ្លាធំ ជាសត្វសាហាវ ស៊ីសាច់ជាអាហារ,
- កន្លង់ ជាសត្វស្លូត,
- ទន្សោងញីឈ្មោល ជាសត្វដ៏កម្រ ហើយមានសម្រស់ស្អាត ដែលតែងត្រូវរងគ្រោះពីសត្វសាហាវដូចជាខ្លា។

**ខ្លឹមសារវប្បធម៌សន្តិភាព**

សិល្បៈរបាំ ជាសិល្បៈមួយប្រកបដោយអត្ថន័យផង ពីរោះផង និង ល្អមើលផង។ តាមខ្លឹមសារនៃប្រវត្តិរឿងរបាំស្នែងទន្សោងនេះ វាមានខ្លឹមសារបណ្ដុះស្មារតីសន្តិភាពយ៉ាងណាដែរ?

សន្តិភាព ជាដំណើរប្រកបទៅដោយភាពស្ងប់ ដំណើរសាន្តត្រាណ ដំណើរមិនមានទំនាស់នឹងគ្នា ឬ ដំណើរសះជានឹងគ្នា។ ក្នុងដំណើររឿងរបាំងស្នែងទន្សោង យើងឃើញថា អ្នកប្រឌិតរឿងនេះបានមើលឃើញច្បាស់ពីស្ថានភាពពិតនៃធម្មជាតិរបស់សត្វ ដែលគាត់បានលើកយកមកធ្វើជាតួអង្គតួយ៉ាងឱ្យស្របនឹងស្ថានភាពតួយ៉ាងរបស់តួអង្គទាំងនោះដែលមានតម្រូវការនិងស្ថិតក្នុងស្ថានភាពងាយនឹងមានទំនាស់នឹងជាគ្នាជានិច្ច។ ខ្លាជាសត្វសាហាវ ស៊ីសត្វឯទៀតជាអាហារដោយមិនលើកលែងឡើយ។ សត្វទាំងឡាយណាដែលបានជួបខ្លាភាគច្រើនត្រូវតែស្លាប់ជាចំណីរបស់វាជាមិនខាន។ ចំណែកឯព្រានព្រៃជាអ្នកប្រកបរបរបាញ់សត្វ សម្លាប់សត្វ ដើម្បីផ្គត់ផ្គង់ជីវភាពរបស់ខ្លួន។ ជាទូទៅព្រានព្រៃក៏មិនសូវលើកលែងឱ្យជីវិតសត្វដែលខ្លួនប៉ងប្រាថ្នាចង់សម្លាប់ឱ្យរួចផុតពីសេចក្ដីស្លាប់ណាស់។ ស្ថានភាពនៃភាពចាំបាច់ទាំងនេះបញ្ជាក់ថា បើអង្គទាំងនេះបានជួបគ្នា ប្រាដកជាមានសត្វណាមួយស្លាប់ជាមិនខាន។ និយាយរួម តួអង្គដូចបានលើកឡើងនេះ ក្នុងស្ថានភាពពិតមិនអាចរួមរស់នៅក្បែរគ្នា ជាមួយគ្នាបានទេ។ ប៉ុន្តែផ្ទុយទៅវិញ អ្នកនិពន្ធបែរជាធ្វើឱ្យដំណើរជីវិតនៃតួអង្គទាំងនេះផ្លាស់ប្ដូរ ខុសប្លែកពីធម្មជាតិទៅវិញ គឺការធ្វើឱ្យតួអង្គទាំងនេះចេះរស់នៅក្នុងបរិយាកាសមួយសប្បាយរីករាយ ភ្លេចនូវការស្រេចឃ្លាន ការកាប់សម្លាប់គ្នាទៅវិញ ដោយតួអង្គកន្លង់ចេះបង្កើតបរិយាកាសសប្បាយរីករាយមួយ ធ្វើឱ្យទន្សោងរេរាំភ្លេចខ្លួនពីសេចក្ដីស្លាប់ ខ្លាដោយឃើញនូវការសប្បាយរីករាយរបស់ទន្សោងញីឈ្មោលក៏ភ្លេចនូវភាព

ស្រេចឃ្លានរបស់ខ្លួនដែលធ្លាប់តែស៊ីសត្វទន្សោងជាអាហារ។ព្រានព្រៃបានឃើញហេតុការណ៍ដ៏អស្ចារ្យនេះ ក៏ភ្លេចសម្លាប់ទន្សោង។ តួអង្គទាំងអស់សប្បាយរៀងៗខ្លួនក្នុងបរិយាកាសថ្មីនេះ គឺសន្តិភាពនឹងគ្នា ហើយ បន្ទាប់ពីបរិយាកាសសប្បាយនេះចប់ ពួកគេក៏វិលទៅលំនៅឋានរៀងខ្លួនវិញអស់។

តាមការបង្ហាញនេះ យើងអាចនិយាយបានថា សេចក្ដីស្លាប់របស់ទន្សោងក្រោមកណ្ដាប់ដៃព្រានព្រៃក៏ដូចជាក្រញុាំដ៏កាចសាហាវរបស់ខ្លាត្រូវបានរួចផុតនេះ ជាផ្នត់គំនិតថ្មីមួយក្នុងសិល្បៈរបាំស្នែងទន្សោង ដែលធ្វើឱ្យយើងពិចារណាដល់ការរួបរួមនៃសត្វដែលធ្លាប់តែជាសត្រូវនឹងគ្នា បែរជាមានបរិយាកាសសប្បាយជាមួយគ្នាដោយគ្មានគិតដល់គ្រោះថ្នាក់អ្វីទាំងអស់ទៅវិញ។ ការធ្វើឱ្យសត្វដែលមិនអាចរួមរស់នឹងគ្នា ឱ្យចេះសប្បាយនឹងគ្នា ចេះរួបរួមសុខសាន្តនឹងគ្នាបែបនេះ ជារបត់នៃផ្នត់គំនិតក្នុងរូបារម្មណ៍មួយស្រឡាញ់សន្តិភាព ស្រឡាញ់បរិស្ថានយ៉ាងពិតប្រាកដ។

សរុបមក ខ្លឹមសារនៃរឿងប្រវត្តិរបាំស្នែងទន្សោងនេះ ពិតជារឿងមួយដែលមានគតិបណ្ឌិតវប្បធម៌សន្តិភាពយ៉ាងពិតប្រាកដ។

## ២.៣- អត្ថន័យសន្តិភាពតាមរយៈការគ្រប់គ្រងនិងនយោបាយ
## - នយោបាយអព្យាក្រឹតរបស់សម្ដេចព្រះនរោត្តម សីហនុ

ប្រទេសកម្ពុជាក្រោយពីបានទទួលឯករាជ្យនៅឆ្នាំ១៩៥៣ សម្ដេចព្រះនរោត្តម សីហនុ ក្នុងពេលព្រះអង្គទ្រង់យាងចូលក្នុងពិធីសន្និសីទកំពូលនៃប្រទេសអាស៊ី-អាហ្វ្រិក នាទីក្រុងបានឌុង ប្រទេសឥណ្ឌូណេស៊ី នាខែមេសា ឆ្នាំ១៩៥៥ ព្រះអង្គបានប្រកាសជាផ្លូវការថា *ព្រះរាជាណាចក្រកម្ពុជាឯករាជ្យបានជ្រើសរើសធ្វើជារដ្ឋអព្យាក្រឹតនិងមិនចូលបក្សសម្ព័ន្ធនៅក្នុងប្លុកនៃប្រទេសឬមហាអំណាចណាមួយឡើយ*[១២]។ការប្រកាសនេះ គឺធ្វើឡើងស្របនឹងចលនាមនោគមវិជ្ជាសេរី និង មនោគមវិជ្ជាកុម្មុយនីស្ដកំពុងតែប្រកួតប្រជែងគ្នានៅក្នុងពិភពលោក ក៏ដូចក្នុងតំបន់ ពិសេសមនោគមវិជ្ជាទាំងពីរនេះបានបាញ់ឆ្ពោះមកប្រទេសទាំងឡាយណាដែលទើបនឹងបានឯករាជ្យថ្មីៗ។ ទាក់ទងនឹងការប្រកាន់យកនយោបាយអព្យាក្រឹតរបស់ប្រទេសកម្ពុជានាសម័យសង្គមរាស្ត្រនិយមនេះដែរ សម្ដេចព្រះនរោត្តម សីហនុ បានមានព្រះរាជបន្ទូលនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៥៧ ក្នុងពិធីអនុសំវច្ឆរៈប្រទានរដ្ឋធម្មនុញ្ញក្នុងឋានៈព្រះអង្គជានាយករដ្ឋមន្ត្រីថា *មានគណៈបក្សនយោបាយមួយចំនួននៅក្នុងប្រទេសកម្ពុជាបាននិយាយថា បើចង់ឱ្យប្រទេសកម្ពុជាមានឯករាជ្យជាតិបរិសុទ្ធ មានស្ថិរភាព ហើយឱ្យពលរដ្ឋខ្មែរមានសាមគ្គីគ្នា ទាល់តែយើងប្រកាន់យកនយោបាយអព្យាក្រឹត។ ព្រះអង្គបានមានបន្ទូលបន្តទៀតថា ក្រោយពីប្រទេសកម្ពុជាប្រកាន់យកនយោបាយអព្យាក្រឹត ពួកគេនាំគ្នាធ្វើសកម្មភាពផ្សេងទៅវិញ គឺខ្លះចង់ធ្វើឱ្យប្រទេសធ្លាក់ទៅក្រោមឥទ្ធិពលកុម្មុយនីស្ដ ខ្លះទៀតចង់ប្រទាញប្រទេសកម្ពុជាឱ្យធ្លាក់ទៅក្នុងប្លុកលោកខាងលិច*[១៣]។

ការប្រកាន់យកនយោបាយអព្យាក្រឹតនៃប្រទេសកម្ពុជាក្នុងដំណាក់កាលនោះ គឺជាគោលការណ៍សន្តិភាពមួយរបស់សម្ដេចព្រះនរោត្តម សីហនុ ដោយព្រះអង្គផ្ដោតទៅលើវិធានការខាងផ្លូវទូតជាងការប្រើវិធីដោះស្រាយបញ្ហាដោយកម្លាំងយោធា និងដើម្បីចៀសវាងភាពច្របូកច្របល់ ស្មុគស្មាញក្នុងបញ្ហា

---

[១២] សុង ស៊ីណា : ***នយោបាយអព្យាក្រឹតនៃព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៥៧ដល់ឆ្នាំ១៩៧០*** ភ្នំពេញ, និក្ខេបបទថ្នាក់បណ្ឌិតប្រវត្តិវិទ្យា ឆ្នាំ២០១១ ទំព័រទី៥៦។

[១៣] សុង ស៊ីណា : ***នយោបាយអព្យាក្រឹតនៃព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៥៧ដល់ឆ្នាំ១៩៧០*** ដ.ឯ.ម. ទំព័រទី៥៧។

សង្គ្រាមត្រជាក់ ដែលប្រទេសដ៏តូចនៃយើងនេះត្រូវបានប្រទាញប្រទង់នៃភាពមិនស្មើគ្នារវាងឥទ្ធិពលមហាអំណាចកំពុងប្រណាំងប្រជែងគ្នាផងដែរ។

ដូចនេះ យើងឃើញថា នយោបាយសន្តិភាពនិងអព្យាក្រឹតនៃប្រទេសកម្ពុជាបាននាំឱ្យប្រទេសនេះទទួលបាននូវការគោរពកោតសរសើរពីសំណាក់ប្រទេសជាច្រើននៅក្នុងពិភពលោកនិងពីសំណាក់ស្រទាប់មហាជនដ៏ទូលំទូលាយថែមទៀតផង។

- **ការបង្រួបបង្រួមជាតិនៃសង្គ្រាមក្នុងប្រទេស**

ប្រវត្តិសាស្ត្រថ្មីបានបង្ហាញឱ្យឃើញថា ប្រទេសកម្ពុជាកើតមានសង្គ្រាមរ៉ាំរ៉ៃជិត៣ទសវត្សរ៍ធ្វើឱ្យប្រទេសរងនូវការបំផ្លិចបំផ្លាញស្ទើរគ្មានសល់ ជីវិតមនុស្សស្លាប់ជាច្រើន ព្រាត់ប្រាសគ្រួសារយ៉ាងអាណោចអាធ័ម។ ដោយសារសង្គ្រាមនេះ បានធ្វើឱ្យសង្គមត្រូវបានបែងចែកជាក្រុមជាពួក ហើយការប្រយុទ្ធគ្នារវាងជាតិសាសន៍ឯងក៏កើតឡើងដើម្បីមនោគមវិជ្ជានៃក្រុមនីមួយៗ។

ទីបំផុតក្រុមដែលមានជម្លោះគ្នាទាំងអស់បានទទួលយកនូវការផ្សះផ្សារជាតិ បង្រួមបង្រួមជាតិពន្លត់ភ្លើងសង្គ្រាម បង្កើតសន្តិភាពតាមរយៈកិច្ចព្រមព្រៀងសន្តិភាពថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នៅទីក្រុងប៉ារីស ដោយមានភាគីខ្មែរដែលមានជម្លោះនឹងគ្នាចូលរួម ក្រោមការឧបត្ថមនៃអង្គការសហប្រជាជាតិនិងប្រទេសហត្ថលេខីចំនួន១៨ផ្សេងទៀត។ ក្រោមកិច្ចព្រមព្រៀងសន្តិភាពនេះ បានធ្វើឱ្យសង្គមខ្មែរឈានទៅរកការរៀបចំប្រទេសតាមរយៈការបោះឆ្នោត ដែលរៀបចំឱ្យអង្គការសហប្រជាជាតិនាឆ្នាំ១៩៩៣ ទោះជាភាគីកម្ពុជាប្រជាធិបតេយ្យបានធ្វើពហិការក្នុងការបោះឆ្នោតនេះក៏ដោយ។

ការបោះឆ្នោតដែលរៀបចំដោយអង្គការសហប្រជាជាតិនេះ ជាលទ្ធផល រាជរដ្ឋាភិបាលថ្មីមួយនៃប្រទេសកម្ពុជាក៏បានកើតឡើងតាមរយៈស្មារតីនៃការបង្រួមបង្រួមជាតិ ស្មារតីសន្តិភាពនិយមគឺការបង្កើតឱ្យមានសហនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្នុងការដឹកនាំប្រទេសនាដំណាក់កាលនោះ។

ទោះជារាជរដ្ឋាភិបាលថ្មីក្រោមកិច្ចព្រមព្រៀងសន្តិភាពថ្ងៃទី២៣ខែតុលាឆ្នាំ១៩៩១បានកើតឡើងមែន ប៉ុន្តែភាគីកម្ពុជាប្រជាធិបតេយ្យមិនបានចូលរួមបោះឆ្នោតជាតិក្នុងឆ្នាំ១៩៩៣ទេ ក្រុមនេះនៅតែបង្កអសន្តិសុខសង្គមដោយសង្គ្រាមឈ្លបនៅតែបន្តក្នុងផ្ទៃប្រទេសធ្វើឱ្យការដឹកនាំប្រទេសជួបការលំបាកក្នុងការអភិវឌ្ឍនិងការស្តារហេដ្ឋារចនាសម្ព័ន្ធឡើងវិញបានឡើយ។ ដោយមានការឈ្លាសវៃក្នុងស្មារតីស្រឡាញ់សុខសន្តិភាព ប្រមុខរាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានអនុវត្តនូវ***នយោបាយឈ្នះៗ*** ដើម្បីបង្រួបបង្រួមជាតិ ដែលនៅពេលនោះសង្គមខ្មែរនៅមិនទាន់មានសន្តិភាពនៅឡើយ។ តាមរយៈនយោបាយឈ្នះៗនេះ អង្គការចាត់តាំងនៃកម្ពុជាប្រជាធិបតេយ្យបានចូលរួបរួមជាមួយនឹងរាជរដ្ឋាភិបាល ធ្វើឱ្យសង្គ្រាមដែលអូសបន្លាយយ៉ាងយូរមកហើយក៏ត្រូវបានបញ្ចប់ទាំងស្រុង ប្រទេសមានសុខសន្តិភាពរហូតមកដល់បច្ចុប្បន្ននិងបន្តជានិរន្តរភាពទៅអនាគតទៀត។

ឆ្លងតាមប្រវត្តិសាស្ត្រនេះ យើងអាចនិយាយបានថា សន្តិភាពពិតជាមានតម្លៃបំផុតសង្គមជាតិនីមួយៗ។

## សន្និដ្ឋាន

ខ្មែរជាជាតិសាសន៍មួយប្រព័ន្ធគំនិតជាអត្តសញ្ញាណជាតិរបស់ខ្លួនតាំងយូរយារណាស់មកហើយ។ តាមរយៈប្រព័ន្ធគំនិតនេះ យើងក៏អាចក្រេបយកនូវគតិបណ្ឌិតអប់រំដ៏ច្រើន ដើម្បីទុកជាមេរៀននៃជីវិតក្នុងការរស់ក្នុងសង្គមថែមទៀតផង។ ទោះជាប្រព័ន្ធគំនិតដែលដូនតាយើងបានបន្សល់ទុកមក មួយចំនួន

មានលក្ខណៈជាអរូបិយក៏ដោយ ប៉ុន្តែវាបានរួមចំណែកផ្ទុះបញ្ជាំងឱ្យយើងបានឃើញពីទស្សនវិជ្ជាខ្មែរពិតៗថា ជាជាតិសាសន៍មួយមានអរិយធម៌ចាស់ទុំ មានការគិតគូរវែងឆ្ងាយសម្រាប់ជីវិតនឹងការរស់នៅរបស់ខ្លួន។ ប្រព័ន្ធគំនិតខ្មែរដែលមានខ្លឹមសារវប្បធម៌សន្តិភាពត្រូវបានរំលេចឡើងតាមរយៈរូបភាពផ្សេងៗជាជំនឿ ជាសិល្បៈចម្លាក់ សិល្បៈសម្តែង ការងារប្រតិបត្តិក្នុងសង្គមជាក់ស្តែង នយោបាយនិងការគ្រប់គ្រងជាដើម។ ការយល់ពីខ្លឹមសារនៃវប្បធម៌សន្តិភាពក្នុងប្រព័ន្ធគំនិតខ្មែរនេះ អាចធ្វើការរស់នៅក្នុងសង្គមរបស់យើងតែងតែមានភាពសុខដុម ការយោគយល់គ្នា អធ្យាស្រ័យគ្នា និង ចេះបង្កើតនូវសន្តិភាពរវាងគ្នានិងគ្នាថែមទៀតផង។

ជារួមយើងអាចវាយតម្លៃបានថា ប្រព័ន្ធគំនិតខ្មែរពិតជាមានបង្កប់ភ្ជាប់នូវខ្លឹមសារសន្តិភាព ទោះជាក្នុងជីវភាពជាក់ស្តែង ប្រជាជនខ្មែរពិតមានគំនិតសន្តិភាពនិយមច្រើនជាងគំនិតហិង្សា គំនិតសម្របសម្រួលក៏ក្លាយជាគោលការណ៍មួយក្នុងការប្រតិបត្តិផ្សេងៗក្នុងសង្គមជាតិផងដែរ។ ដូចនេះ ការបង្កើតវប្បធម៌សន្តិភាពជាការចាំបាច់បំផុតក្នុងសង្គមជាតិនីមួយៗ។ ប៉ុន្តែយើងគួរតែយល់ថា ការធ្វើឱ្យមានសន្តិភាពនេះ គឺត្រូវផ្តើមចេញពីភាពស្ងប់ជាចម្បងមានន័យថា *បើបុគ្គលម្នាក់ៗស្ងប់ នាំឱ្យគ្រួសារមួយស្ងប់ បើគ្រួសារនីមួយៗស្ងប់ នាំឱ្យសហគមន៍មួយស្ងប់ បើសហគមន៍នីមួយៗស្ងប់ នាំឱ្យប្រទេសមួយស្ងប់ បើប្រទេសនីមួយៗស្ងប់ នាំឱ្យពិភពលោកស្ងប់ សន្តិភាពនឹងកើតមានទាំងអស់គ្នា។*

ពាក្យសន្តិភាពមិនមែនមានន័យត្រឹមតែអវត្តមានសង្គ្រាមនោះទេ កាលណានិយាយពីសន្តិភាពយើងត្រូវគិតដល់សន្តិភាពផ្លូវចិត្តផងដែរ គឺការគ្មានការគំរាមកំហែងផ្នែកអារម្មណ៍និងគ្មានការភ័យខ្លាចមានន័យថា សេរីភាពនៃការគិត ការបញ្ចេញមតិ ការជួបជុំ ជំនឿរបស់បុគ្គលម្នាក់ៗអាចជឿទុកចិត្តបាន។ យ៉ាងនេះ បុគ្គលម្នាក់ៗត្រូវតែចេះថែរក្សាសន្តិភាពឱ្យបានគង់វង្សបន្តជានិរន្តរ៍ គឺត្រូវ ៖

- ចេះកសាងសមិទ្ធផលដែលទ្រទ្រង់ដល់វិស័យវប្បធម៌សន្តិភាព ដូចជា តាមរយៈស្នាដៃអក្សរ-សាស្ត្រ អក្សរសិល្ប៍ វិទ្យាសាស្ត្រ  សិល្បៈ ជំនឿ ជាដើម។

- ចេះបណ្តុះគំនិតដល់យុវជនឱ្យស្រឡាញ់វប្បធម៌សន្តិភាព តាមរយៈការធ្វើឱ្យសង្គមមានយុត្តិធម៌ សមធម៌ បំបាត់អំពើពុករលួយ ក្នុងសង្គមជាតិរបស់ខ្លួនឱ្យបានជាអតិបរមា ហើយក៏មិនត្រូវមានគំនិតរើសអើងវប្បធម៌ ជាតិសាសន៍ដទៃដែរ។

- ចេះផ្សព្វផ្សាយនូវអ្វីដែលមានលក្ខណៈវប្បធម៌សន្តិភាពដល់មហាជន ពិសេស យុវជន កុមារទោះជាតាមកម្មវិធីសិក្សាឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ជាដើម។

- ចេះការពារសម្បត្តិធម្មជាតិរបស់ជាតិឱ្យបានគង់វង្ស សម្បត្តិធម្មជាតិដែលសំខាន់ជាងគេគឺ ***មនុស្សខ្មែរ*** កុំបង្កសង្គ្រាមនាំឱ្យមានការសម្លាប់មនុស្សខ្មែរគ្នាឯង ត្រូវបង្កើនសាមគ្គីភាពផ្ទៃក្នុង កុំគិតតែពីប្រយោជន៍សួនតួនិយម ត្រូវគិតប្រយោជន៍ជាតិជាធំ។

## គន្ថនិទ្ទេស


- ជួន ណាត : ***វចនានុក្រមខ្មែរភាគ១-២*** ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧។
- ជុច ភឿន : ***មនុស្ស សិល្បៈ ជំនឿ*** ភ្នំពេញ, ការផ្សាយរបស់គណៈកម្មការស្រាវជ្រាវសាកលវិទ្យាល័យវិចិត្រសិល្បៈ, ឆ្នាំ១៩៩៣។

- ចាប ពិន, ពេជ្រ សល់, លី ធាមតេង និង ស្ដើង ធូរ : *របាំប្រជាប្រិយខ្មែរ* ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពលើកដំបូង ឆ្នាំ១៩៦៤។
- ប៉ាង ខាត់ : *ស្រីហិតោបទេស ភាគទី៤* ភ្នំពេញ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៩៤។
- មីសែល ត្រាណេ : *ប្រព័ន្ធគំនិតខ្មែរភាគ១* ភ្នំពេញ, រោងពុម្ព [?], ឆ្នាំ១៩៩៨។
- សុខ ប៊ុនធឿន : *ប្រព័ន្ធច្បាប់ខ្មែរ* ភ្នំពេញ, ឆ្នាំ២០១៤។
- សុង ស៊ីណា : *នយោបាយអព្យាក្រឹតនៃព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៥៧ដល់ឆ្នាំ១៩៧០* ភ្នំពេញ, និក្ខេបបទថ្នាក់បណ្ឌិតប្រវត្តិវិទ្យា ឆ្នាំ២០១១។
- បេតិកភណ្ឌពិភពលោកក្នុងដៃយុវជន ស្គាល់ ស្រឡាញ់ និង ធ្វើសកម្មភាព, នៅក្នុងអត្ថបទ : ‹*បេតិកភណ្ឌពិភពលោកនិងវប្បធម៌សន្តិភាព*› ផ្សាយដោយអង្គការយូណេស្កូ ឆ្នាំ១៩៩៩។